# ស្រមោលអន្ទោលច្រាណា

***Loneliness***

*ជឿទេ... ភាពឯកោអាចសម្លាប់មនុស្ស?*
*មនុស្សដែលនៅជុំវិញនាង សុទ្ធតែត្រូវបានចាកចេញ និង ត្រៀមខ្លួនសម្រាប់ការចាកចេញដោយគ្មានថ្ងៃត្រលប់...*

អានន្ទ
ផ្កាកែវ
មុទិតា(អ្នកបម្រើ)
ម៉ាក់អ៊ំ

អានន្ទ គឺជាប្រភេទមនុស្សប្រុសម្នាក់ ដែលនរណាឃើញហើយ ក៏នាំគ្នាសន្និដ្ឋានក្នុងផ្លូវតែមួយថា «គ្មានពិសពុល» អ្វីទាំងអស់។ មុខមាត់របស់គេចាត់នៅក្នុងកម្រិតមួយដែលមិនរាប់ថាសង្ហាហើយក៏មិនចាត់ទុកថាអាក្រក់អ្វីដែរ។ រូបរាងមិនស្គមតែក៏មិនធាត់ មិនខ្ពស់តែក៏មិនទាប លក្ខណៈសមល្មមបែបកណ្ដាលៗដូច្នេះ នៅពេលបូកផ្សំជាមួយរសនិយមតុបតែងខ្លួន បែបសុភាពរាបសាទៀតនោះ ធ្វើឲ្យគេមើលទៅជាកំលោះវ័យ២៥ឆ្នាំ ដែលគ្មានអ្វីវិសេសវិសាលគួរឲ្យកត់សម្គាល់ឡើយ។ មនុស្សជាច្រើនលួចនិយាយនិន្ទាពីក្រោយខ្នង ដោយនាំគ្នាសន្និដ្ឋានផ្សេងៗច្រើនបែបច្រើនយ៉ាង ថា ជីវិតរបស់គេជាជីវិតដែលអត់ជាតិអត់ជាតិសោះ។

អានន្ទ ធ្វើការផ្នែកគណនេយ្យ របស់ក្រុមហ៊ុនស្វែងរកការងារតូចមួយកន្លែង នៅជាន់ក្រោមដីរបស់អគារខ្ពស់ស្កឹមស្កៃមួយកណ្ដាលក្រុងភ្នំពេញ។ ក្រុមហ៊ុននេះ ជាក្រុមហ៊ុនមួយដ៏សែនស្ងប់ស្ងាត់។ ជីវិតរបស់វាក៏មិនខុសអ្វីពី អានន្ទ ដែរ។ ច្រើនគ្រាមកហើយដែលមនុស្សមកទាក់ទងការងារ រកមិនជួបព្រោះតែការលាក់ខ្លួននៅទីកំបាំងចុងគេនៃជាន់ក្រោមបំផុត... ដែលការពិតនោះត្រូវបែងចែកឲ្យនៅក្នុងផ្នែកមួយនៃអាហារដ្ឋានសម្រាប់បុគ្គលិករបស់អគារធំ។

រៀងរាល់ព្រឹករបស់ អានន្ទ ចាប់ផ្ដើមនៅម៉ោង [៥:៣០] នាទី។ សំឡេងនាឡិការោទិ៍ឮខ្ទររំពួយពេញបន្ទប់ស្នាក់នៅតូចៗក្នុងតម្លៃជួលថោកៗ... កំលោះផ្លាស់មករស់នៅក្នុងផ្ទះល្វែងនេះកាលពីពីរឆ្នាំមុន ក្រោយពីម្ដាយដែលជាញាតិតែម្នាក់គត់របស់ខ្លួនបានចែកឋានទៅ... គេប្រញាប់ស្លៀកពាក់រត់ទៅហៅម៉ូតូឌុបជិះទៅក្រុមហ៊ុនដែលប្រដូចទៅនឹងផ្ទះទីពីរ...ផ្ទះដែលមានតែភាពស្ងប់ស្ងាត់... មានមនុស្សដើរទៅមកជុំវិញខ្លួនតែត្រលប់ជាគ្មាននរណានិយាយគ្នា។ មួយថ្ងៃៗ កន្លងផុតទៅតាមលម្អានគោចររបស់ព្រះអាទិត្យ... តែពេលខ្លះសែនយឺតយូរ... ពេលខ្លះទៀតមហាលឿនដូចព្យុះកំបុតត្បូង។

បើពិនិត្យឲ្យដល់ទៅ គឺអាស្រ័យលើថ្ងៃនោះ មានអ្វីជាការទន្ទឹងរង់ចាំ ឬអត់។ ក្រោយពីអស់ម៉ោងធ្វើការនៅម៉ោងប្រមាណ [១៧:៣០] នាទី អានន្ទនឹងត្រលប់ទៅផ្ទះ។

«ប្រហែលមើលទូរទស្សន៍ចប់ក៏ចូលដេកហើយ!»

«ច្បាស់ជាគ្មានកន្លែងទៅដូចអ្នកដទៃទេ!»

នោះគឺជាសំឡេងខ្សឹបខ្សៀវគ្នា ក្រោយពីអានន្ទចេញផុតទៅ។

គ្មាននរណាធ្លាប់ដឹងការពិតទេថា នៅពីក្រោមស្រោមមុខមឹះៗឥតជាតិជៅ បែបសោះអង្គើយស្ងាត់ស្ងៀមមិនមាត់មិនកដូច អានន្ទ នៅមានរឿងរ៉ាវមិនគួរឲ្យជឿមួយចំនួនទៀត បង្កប់នៅពីក្រោយនោះ...

អានន្ទ នៅក្នុងចន្លោះពេល ពីម៉ោង [៥:៣០] ដល់ម៉ោង [១៧:៣០] និង អានន្ទ នៅក្នុងរយៈពេលក្រោយពីនោះ ប្រៀបដូចស្រមោលនិងពន្លឺ។

បើសាកល្បងសង្កេតឲ្យបានច្បាស់ យើងនឹងឃើញថា ជីវិតរបស់មនុស្សគឺបែបនេះ! នៅសម្បកខាងក្រៅ បើមិនបានសង្កេតមើលឲ្យស៊ីជម្រៅ នៅមានរូបរាងរបស់យើងដែលកំពុងលង់លក់យ៉ាងស្ងប់ស្ងាត់នៅក្នុងពិភពមួយទៀត... រូបរាងនោះប្រៀបដូចស្រមោលកប់បញ្ច្រាសទិស ដែលកំពុងរង់ចាំថ្ងៃបើកចំហឲ្យគ្រប់គ្នាបានស្គាល់...

គ្រប់គ្នានោះមានរួមទាំងយើងខ្លួនឯងផង!

អានន្ទ ស្គាល់ និង រំលាយរូបរាងមួយទៀតនោះ ជាមួយប្រព័ន្ធអ៊ីនធើណេតយ៉ាងងប់ងល់។

សព្វថ្ងៃ Facebook បើកទូលាយពិភពលោកឲ្យមនុស្ស ដែលមិនធ្លាប់ជួបមុខគ្នា ដើរចេញពីពិភពងងឹតមកចាប់ដៃគ្នាធ្វើជាមិត្តភក្តិបាន។ តែសម្រាប់ អានន្ទ...

អាចធ្វើបានលើសពីនេះទៅទៀត!

រូបរាងមួយទៀតរបស់ អានន្ទ គឺជាព្រាននារីដែលមានឫកពាម៉ឺងម៉ាត់ប្រាកដប្រជា។ កំលោះមានល្បិចរាយអន្ទាក់ស្នេហ៍គ្រប់កលវិធី ក្នុងការបោកបញ្ឆោតឲ្យក្រមុំៗ ដែលមានបេះដូងរងាងកោតាមទំព័រ Facebook ឈានជើងចេញពីអេក្រង់កុំព្យូទ័រមកបង្ហាញមុខមាត់ពិត នៅក្រៅទំព័រអ៊ីនធើណេត។ គេចេះនិយាយលែបខាយសម្ដី ចោលផ្កាវាចាយ៉ាងប៉ិនប្រសប់ បង្កប់ដោយអត្ថន័យដែលអាចធ្វើឲ្យដៃគូសន្ទនាយល់ដល់តម្រូវការដែលលាក់ទុកក្នុងពាក្យពេចន៍ទាំងនោះ។

បើត្រូវរ៉ូវគ្នា... គឺទៅបន្ត!

បើជ្រួសផ្លូវក៏មិនឲ្យខាតពេល... ស្វែងរកនុយថ្មីភ្លាម!

នៅក្នុងពិភពខាងក្រៅ អានន្ទគ្រាន់តែជាអាមុខស្លេកមឹះៗម្នាក់ប៉ុណ្ណោះ តែនៅក្នុងពិភពដែលគេបង្កើតឡើងដោយខ្លួនឯង... អានន្ទ គឺជាព្រាននារីដ៏ពិសពុលម្នាក់។

* * *

ផ្កាកែវ គឺជាក្មេងស្រីដែលទើបតែមានអាយុឈានចូល១៦ឆ្នាំកាលពីប៉ុន្មានថ្ងៃមុននេះ។ សភាពទន់ខ្សោយរបស់ រាងកាយ និង ផ្លូវចិត្ត ធ្វើឲ្យឪពុកម្ដាយជាមហាសេដ្ឋីទាំងពីរ ជួលគិលានុបដ្ឋាយិកាដែលមានចំណេះដឹងគ្រប់គ្រាន់ អាចធ្វើជាគ្រូបង្រៀនផង និង ជាអ្នកមើលថែរក្សានាងផងក្នុងពេលតែមួយ។ ការបានរស់នៅជាមួយគ្នាជិត៧ឆ្នាំ ធ្វើឲ្យ មុទិតា គិលានុបដ្ឋាយិកាដ៏សែនចិត្តល្អ ល្មមអាចយល់បានថា ហេតុអ្វី ផ្កាកែវ មិនយំសោកសង្រេង ចំពោះការបាត់បង់ជីវិតរបស់ឪពុកម្ដាយកាលពី៦ខែមុន។

បើនិយាយទៅ… រវាងលោកបញ្ញៈ អ្នកស្រីពណ៌ និង កូនស្រី ហាក់ដូចជាមានខ្សែឆ្មារអ្វីម្យ៉ាងខណ្ឌពួកគេមិនឲ្យហ៊ាននៅជិតគ្នាប៉ុន្មានទេ។ ផ្កាកែវ ជាក្មេងស្រីធំមុនអាយុ គំនិត និងការនិយាយស្ដីមិនសូវមាននរណាជឿថា នាងទើបតែមានអាយុ១៦ឆ្នាំទេ។

វាត្រូវតែអ៊ីចឹង… ព្រោះអ្នកទាំងនោះស្គាល់នាងមិនច្បាស់ដូច មុទិតា ស្គាល់។

មុទិតា ស្រលាញ់ និង ស្និទ្ធស្នាល ជាមួយ ផ្កាកែវ ដូចបងស្រីបង្កើត ទោះបីជាពេលខ្លះ ផ្កាកែវ ឆេវឆាវ និងខឹងមួម៉ៅ ដោយគ្មានហេតុផល តែ មុទិតា នៅតែអត់ធន់បាន។ ទាំងនេះ អាចមកពីសេចក្ដីអាណិតអាសូរ និង ការសន្ដោសប្រោសប្រណី ដែលនាងមានចំពោះនាងតូចក៏ថាបាន។

ផ្កាកែវធំធាត់តាមរបៀបក្មេង ដែលត្រូវឪពុកម្ដាយបោះបង់ចោល មិនសូវខ្វាយខ្វល់ជាមួយ ដោយមានហេតុផលថាជាប់រវល់ការងារ។ លុះច្រើនដងពេកទៅ មុទិតា ក៏តាមដានដឹងថា អ្នកទាំងពីរចេញទៅក្រៅ ដើម្បីលួចទៅដើរកម្សាន្តផ្អែមល្ហែមជាមួយគ្នាតែពីរនាក់តទល់ប៉ុណ្ណោះ។

ប្រហែលជាកម្មពៀរ ដែលធ្វើឲ្យក្មេងស្រី ទាំងស្រស់ស្អាត ទាំងឆ្លាត ទាំងមាន ត្រូវមកជួបជីវិតបែបនេះ។

ផ្កាកែវ មានជំងឺបេះដូង និង ជំងឺផ្សេងៗទៀតរាប់មិនអស់ ជាពិសេសជំងឺ… ឬបើឲ្យនិយាយទៅ… វាជាអ្វីម្យ៉ាងដែលមិនទាន់មាននរណាអាចពន្យល់ហេតុផលបាន… ផ្កាកែវមានអ្វីម្យ៉ាងនោះដែលជាឧបសគ្គរាំងដល់ដំណើរការជីវិតប្រចាំថ្ងៃ… សភាពផ្លូវចិត្តច្បាស់ជាត្រូវគ្រាំគ្រាច្រើនជាងនេះ បើបណ្ដោយឲ្យក្មេងតូចចេញទៅជួបទាក់ទងជាមួយមនុស្សនៅខាងក្រៅ។

*ជួនកាលនៅកណ្ដាលចំណោមមនុស្សម្នាជាច្រើន… មនុស្សយើងកាន់តែឯកោជាងនៅម្នាក់ឯងទៅទៀត…*

ពិភពលោករបស់ ផ្កាកែវ មាន មុទិតា និង ម៉ាក់អ៊ំ ម្នាក់ទៀតដែលតែងតែទូរស័ព្ទមកសួរសុខទុក្ខ និងចាត់ចែងកេរមរតកទាំងអស់ ក្រោយពីឪពុកម្ដាយរបស់ក្មេងស្រីចែកឋានទៅ។ មុទិតា ដឹងថាការពិតម៉ាក់អ៊ំរបស់ ផ្កាកែវ គ្មានបំណងល្អទេ។ ពេលខ្លះនាងហាក់ដូចជាល្ងង់ដែលយករឿងនេះទៅនិយាយជាមួយ ផ្កាកែវ… និយាយទាំងដឹងថា ផ្កាកែវ នៅក្មេង និងអាចជាហេតុផលធ្វើឲ្យក្មេងស្រីបាត់បង់ការគោរព និងជឿជាក់ ចំពោះញាតិសន្ដានដែលនៅសល់តែម្នាក់នេះ។

ហេតុដូច្នេះ គំនិតទាំងអស់នេះក៏រលាយបាត់យ៉ាងឆាប់រហ័ស ហើយត្រលប់ក្លាយជាអារម្មណ៍ភ័យរន្ធត់វិញ នៅពេល ផ្កាកែវ ជាអ្នកនិយាយដោយខ្លួនឯងថា៖

«គ្មានបញ្ហាកើតឡើងយូរដល់ថ្នាក់នោះទេ… បងតា!!»

ក្រៅពីអ្នកទាំងពីរ... កុំព្យូទ័រ និង អ៊ីនធើណេត បានបើកចំហជើងមេឃឲ្យ ពិភពលោកដ៏តូចចង្អៀតរបស់ផ្កាកែវ រសាយភាពឯកោបានខ្លះៗ។

ក្មេងសម័យនេះ ប្រើប្រព័ន្ធតិចណូឡូជីយ៉ាងស្ទាត់ជំនាញ... មុទិតា គិតនៅក្នុងចិត្តគ្រប់ពេលដើរកាត់បន្ទប់ហើយឃើញ ផ្កាកែវ នៅអង្គុយជាប់នឹងអេក្រង់កុំព្យូទ័រ។ ស្រីតូចតែងប្រាប់ថានាងកំពុងលេងហ្គេម តែបើ មុទិតា នឹកសង្ស័យហើយដើរចូលទៅជិតបន្តិចនឹងឃើញថា...

នោះគឺជាគេហទំព័រ Facebook!!

* * *

អានន្ទ ស្គាល់ ផ្កាកែវ ច្រើនសប្តាហ៍មកហើយ។ នុយចុងក្រោយនេះប្លែកណាស់ ព្រោះគេបាន Email Address មកពីទំព័រ «ព្រះធម៌ និង ពុទ្ធសាសនា»។

«មនុស្សយើងរស់នៅមានប្រយោជន៍អី បើទីបញ្ចប់...សូម្បីតែខ្យល់ដកដង្ហើមក៏មិននៅសល់!»

ចំណងជើងគួរឲ្យចាប់អារម្មណ៍មួយនេះ ដែលជាដើមហេតុនាំឲ្យអ្នកទាំងពីរបានស្គាល់គ្នា។

ផ្កាកែវ គឺជាដៃគូសន្ទនាដែលចម្លែកខុសពីអ្នកមុនៗ ដែល អានន្ទ ធ្លាប់ជួបកន្លងមក។ នាងប្រាប់ថា ទើបតែមានអាយុ១៦ឆ្នាំ តែកំលោះទាយថា នោះគ្រាន់តែជាសម្តីកុហកប៉ុណ្ណោះ ព្រោះបើសង្កេតតាមការនិយាយស្តី នាងគួរតែមានអាយុលើសពី២០ឆ្នាំ។ រឿងរ៉ាវដែល ផ្កាកែវ ចូលចិត្តលើកមកពិភាក្សា គឺទៅណាមិនឆ្ងាយពីរឿងស្លាប់រស់នោះទេ។

«ហេតុអ្វី បានជាចូលចិត្តនិយាយតែរឿងព្រឺន្ធត់ៗ បែបនេះ?» ច្រើនដងហើយដែល អានន្ទ មួម៉ៅ ហើយនិយាយចេញទៅដោយទប់មិនបាន។ ការនិយាយគ្នាតែបញ្ហាធម៌អាថ៌បែបនេះ មិនបានធ្វើឲ្យកំសួលអារម្មណ៍របស់គេកម្រើកឡើងម្តងណាទេ។

«បង នន្ទ ធុញហើយមែនទេ?» អានន្ទ ស្រមៃទៅដល់រូបភាពដែល ផ្កាកែវ និយាយកាត់សម្តីដោយការអាក់អន់ចិត្ត។

«កុំប្រញាប់ធុញនឹង កែវ អី! ជួនកាលមកពីជីវិតរបស់ កែវ មានតែរឿងបែបនេះនៅវិលវល់ជុំវិញខ្លួនពេក...»

«នៅធ្វើចិត្តរឿង ម៉ាក់អ៊ំ មិនទាន់បានទៀតឬ?» កំលោះនឹកទៅដល់ដំណឹងមរណភាពរបស់សាច់ញាតិចុងក្រោយតែម្នាក់ ដែលម្ចាស់ខ្លួននិយាយប្រាប់... បើរឿងទាំងអស់ដែល ផ្កាកែវ និយាយប្រាប់ជារឿងពិត ជីវិតរបស់នាងគឺពិតជាអភ័ព្វមែន... មនុស្សស្អី ឪពុកម្តាយញាតិមិត្តបងប្អូនស្លាប់ចោលទាំងអស់ នៅសល់តែខ្លួនឯងម្នាក់ដែលឈឺម្តេតៗ គួរឲ្យអាណោចអាធ័ម...

មែនហើយ វាគួរឲ្យអាណោចអាធ័ម រហូតគេគិតថានាងនិយាយកុហក!

ជួនកាល... មាយារបស់មនុស្សស្រីមានប្លែកៗ ឯនាង ផ្កាកែវ ស្អីគេនេះ ប្រហែលជាគិតថា វិធីនិយាយស្តីបែបនេះ អាចធ្វើឲ្យខ្លួនឯងមើលទៅកាន់តែគួរឲ្យអាណិតទេដឹង?? ក្រោយៗមកនេះ ឮតែនិយាយច្រំដែលៗ ថា ចង់ស្លាប់ៗ រហូតធ្វើឲ្យគេធុញទ្រាន់ស្ទើរតែឈប់ចង់និយាយជាមួយទៅហើយ!!

«មិនប្រាកដដែរ គ្រាន់តែមួយរយៈនេះ មានរឿងធ្វើឲ្យមិនសប្បាយចិត្ត អផ្សុកឯកោ... រហូតធុញទ្រាន់នឹងជីវិតទៀតហើយ...»

ទៀតហើយ... ចូលចិត្តនិយាយមើលតែខ្លួនឯងប្រុងទៅសម្លាប់ខ្លួន។ បើរាប់មិនខុសទេ អានន្ទគិតថា នេះប្រហែលជាការស្លាប់លើកទី ៣៨ ហើយ ប្រសិនបើនាងធ្វើពិតមែន!

តែណ្ហើយ! មិនថាយ៉ាងណា... មុននឹងស្លាប់ក៏សុំឲ្យបាន «ប៉ះគ្នា» ម្តងពីរសិនក៏ល្អដែរ! ហាសហាសហា...

«អឺ... អូន កែវ កុំគិតបែបនេះអី! ធ្វើអ៊ីចែសល្អទេ... ពេលទំនេរៗយើងទៅមើលកុនជាមួយគ្នាក៏បាន គេថាភាពឯកោ ធ្វើឲ្យមនុស្សយើងចិត្តរាយមាយណ៎ា!»

«កែវ មិនហ៊ានចេញពីផ្ទះទេ!»

«ហេតុអីទៅ? គ្រាន់តែចេញមកមើលកុនជាមួយគ្នាប៉ុណ្ណោះ ឬមួយមិនចង់ជួបគ្នា?» អានន្ទធ្វើជាងរ។

«ចាំស! មិនមែនទេ កែវ ចង់ជួបបង នន្ទ ខ្លាំងណាស់!»

ស្រស់ស្រីស្ងាត់មួយសន្ទុះ។

«បែបនេះវិញយ៉ាងម៉េចដែរ... ស្អែកនេះ បងនន្ទ មកជួប កែវ នៅឯផ្ទះបានទេ... បងនន្ទ នៅចាំអាសយដ្ឋានដែល កែវ ធ្លាប់ប្រាប់ពីលើកមុនហើយឬនៅ?»

ហាសៗ... ឈប់លេងខ្លួនទៀតទៅនាងច្រមក់!!

«បាទ... បងចាំបាន!»

«បង នន្ទ មកថ្ងៃស្អែកនេះតែម្តងបានទេ? មកឲ្យដល់មុន...»

ស្ងាត់ម្តងទៀត។

«មុនអីទៅ??»

«ចាំស... មុនថ្ងៃត្រង់! មកផ្ទះ កែវ ឲ្យបានមុនថ្ងៃត្រង់ណ៎ា... កែវ នឹងរង់ចាំ!»

ឆ្កួតមែន!! ថ្ងៃស្អែកនេះជាថ្ងៃអាទិត្យ មាននរណាក្រោកពីព្រលឹមនោះ? ហើយអាសយដ្ឋានដែលនាងច្រមក់ប្រាប់ ក៏នៅឆ្ងាយទៀត ទម្រាំតែទៅដល់ក៏ត្រូវប្រើពេលវេលាដែរ!

តែក៏ល្អម្យ៉ាង... ការទៅដល់មុនបន្តិច អាចមានពេលលួងលោមនាងច្រមក់ កែវ ឲ្យចេញពីល្ហាង... មកកន្លែងដែលងាយស្រួលប្រតិបត្តិការងារជាង។

ណ្ហើយ... បើស្ថានការណ៍អំណោយផល...

គេនឹងយកមកគិតម្តងទៀត!

* * *

ច្រើនថ្ងៃមកហើយ ដែល មុទិតា ឃើញ ផ្កាកែវ សម្ងំជូតទឹកភ្នែកនៅមុខកុំព្យូទ័រ។ នាងតូចមិនព្រមប្រាប់ទេថា មានរឿងអីកើតឡើង? បើតាមសម្ដីបន្តិចបន្តួចកាលពីល្ងាចថ្ងៃមុន ធ្វើឲ្យ មុទិតា អាចស្មានដឹងដោយខ្លួនឯងថា ជំងឺឯកោរបស់ ផ្កាកែវ ចាប់ផ្ដើមកម្រើកទៀតហើយ។

«មូលហេតុអីក៏មិនដឹង... ហេតុអ្វី បានជាគ្មាននរណាមកយក ផ្កាកែវ ទៅអ៊ីចឹង កាលបើយកមនុស្សជុំវិញផ្កាកែវទៅអស់ហើយ!»

«អូនកែវ!» ទោះបីជាធ្លាប់ឮសម្ដីនេះដារៀយៗម្ដងហើយម្ដងទៀត តែរាល់លើក មុទិតា នៅតែអត់ស្លុតចិត្តមិនបាន «និយាយអីដូច្នេះ ជីវិតមនុស្សយើងមានតម្លៃណាស់!»

«អាចជាជីវិតអ្នកដទៃ ដែលមិនមែនជា កែវ... ជីវិតរបស់ កែវ ស្លាប់រស់នៅតែក្នុងផ្ទះ ធ្វើអ្វីក៏មិនបាន គ្រាន់តែដើរលឿនបន្តិចក៏ទៅជាខ្យល់ចាប់។ កែវ ចង់សាកល្បងចេញទៅធ្វើអ្វីៗនៅខាងក្រៅដូចដែលគេឯងគ្រប់គ្នាធ្វើដែរ...»

កន្ទុយសំឡេងស្អកស្អា ខ្សែភ្នែកពោរពេញដោយភាពសោកសៅ ធ្វើឲ្យមុទិតាបានត្រឹមតែដកដង្ហើមធំ។

ម្នាក់ៗសុទ្ធតែដឹងថាគ្មានផ្លូវអាចទៅរួច... រវាង ផ្កាកែវ និង ពិភពខាងក្រៅ ហាក់ដូចជាមានកំផែងធំខ្ពស់នៅខណ្ឌចំកណ្ដាល។

បើនិយាយដល់រឿងនេះ... គ្រាន់តែសម្លឹងភ្នែកគ្នាក៏ឃើញរូបភាពចាស់ៗលេចជាស្រមោលរឿងរ៉ាវឡើង។ លើកចុងក្រោយ ដែល ផ្កាកែវ ចេញទៅក្រៅ គ្រាន់តែឈានជើងចេញទៅដល់មាត់ផ្លូវរឿងរ៉ាវនឹកស្មានមិនដល់ក៏កើតឡើងមួយរំពេច។

«បង... ប្រយ័ត្ន!!»

សំឡេង ផ្កាកែវ ស្រែកភ្លាត់សំឡេង នៅរណ្ដំរងំក្នុងអារម្មណ៍។ មុទិតា នៅចាំដល់ហេតុការណ៍ដែលនាងឃាត់ក្មេងស្រី មិនឲ្យស្ទុះទៅរកនារីម្នាក់ ដែលកំពុងដើរនៅកណ្ដាលថ្នល់។ មិនទាន់ផុតសំឡេងផង សសរឈើពុកធំមួយ ដួលរលំមកសង្កត់នារីម្នាក់នោះ ស្លាប់នៅនឹងកន្លែងភ្លាមៗ។ ជំងឺបេះដូងរបស់ ផ្កាកែវក៏កម្រើកមួយរំពេច នឹងហេតុការណ៍ដែលបានកើតឡើង។

«អូន កែវ កុំគិតច្រើនអី...» គ្មានពាក្យពេចន៍អ្វីទៀត ដែល មុទិតា អាចលួងលោមបានច្រើនជាងនេះ... តាំងពីពេលមុន រហូតមកដល់ឥឡូវ ក៏នៅតែគ្មាន...

គ្មានវិធីណាដែលធ្វើឲ្យតំណក់ទឹកថ្លាៗ រលាយបាត់ពីកែវភ្នែកទាំងគូរបស់ ផ្កាកែវ ឡើយ...

* * *

ទម្រាំ អានន្ទ ភ្ញាក់ ពេលវេលាក៏កន្លងទៅ រហូតម៉ោង [10:30] ទៅហើយ។ កំលោះប្រញាប់ស្ទុះស្ទាក្រោកឡើងយ៉ាងរហ័សរហួន នៅពេលដឹងថា មានណាត់ជាមួយនុយថ្មីមុនពេលថ្ងៃត្រង់ ហើយក៏រួសរាន់រៀបចំសម្អិតសម្អាងខ្លួនត្រៀមជួបការណាត់គ្រាសំខាន់។

«លើកនេះនឹងបានស្គាល់គ្នាហើយ នាងច្រមក់ កែវ! បងនឹងនាំអូនឲ្យស្គាល់ឋានសួគ៌មុននឹងស្លាប់!»

* * *

ផ្កាកែវ ក្រោកពីព្រឹកខុសប្រក្រតី ចាំមើលទ្រនិចនាឡិកា ហើយជ្រួលច្រាលឲ្យ មុទិតា ធ្វើនំនែកយ៉ាងច្រើនពោរពាស រហូតធ្វើឲ្យអ្នកមើលការខុសត្រូវអត់ធ្ងល់មិនបាន។

«ដឹងហើយអូនកែវ... អូនកែវប្រាប់បងតាំងពីម្សិលម្ង៉ៃ គ្រប់យ៉ាងរៀបរយអស់ហើយ! និយាយអ៊ីចឹង អូនកែវប្រាប់បងបានឬទេថា មានរឿងអី? ហេតុអ្វី អូនកែវ ប្រាប់ឲ្យបងធ្វើស្ទើរតែចលាចលបែបនេះ??»

គ្មានចម្លើយពីបុគ្គលដែលត្រូវសួរ។ ផ្កាកែវ ឈ្ងោកមុខនៅស្ងៀម សម្លឹងមើលទ្រនិចនាឡិកា ហើយភ្ញាក់ស្មារតីព្រើតនៅពេលឃើញថា ពេលវេលាកន្លងមកដល់ម៉ោង [11:00] ទៅហើយ។

* * *

រថយន្តតាក់ស៊ី ជួយបំព្រួញពេលវេលាបានច្រើនណាស់ ត្រឹមតែកន្លះម៉ោងប៉ុណ្ណោះ អានន្ទ ក៏មកដល់មាត់ផ្លូវចូលផ្ទះរបស់ ផ្កាកែវ ទៅហើយ។ ខណៈកំពុងសម្លឹងមើលទៅមាត់ច្រកដែលបើកទូលាយ កំលោះភាំងស្មារតីយ៉ាងចម្លែក ព្យាយាមរកចម្លើយឲ្យខ្លួនឯង ថា ប្រហែលជាមកពីភាពរុងរឿងមហិមាដែលមិនធ្លាប់ជួបពីមុនមកនេះហើយ។

អឺ... ហ៊ឹមមម... ជួនកាលនុយមួយនេះ អាចនាំមកនូវជោគលាភច្រើនជាងភាពត្រេកត្រអាលទៅទៀត។

ត្រីធំនៅត្រឹមចុងម្រាមដៃ នរណាដែលមិនស្រវាចាប់? ណ្ហើយ! ចាំដល់ពេលទៅអង្គុយក្រោមពន្លឺភ្លើងទៀនតែពីរនាក់សិនចុះ គេនឹងចាប់ទះគូទឲ្យរាងចាលម្តង ដែលហ៊ានបង្កបញ្ហាបោកបញ្ឆោតគេយ៉ាងច្រើនសន្ធឹកសន្ធាប់។

អានន្ទ មើលនាឡិកា... ពេលណាត់គឺមុនថ្ងៃត្រង់ តែពាក្យថា«មុន» មិនមែនជាពាក្យដែលបញ្ជាក់ពីបរិមាណតិច ឬច្រើន ការទៅយឺតបន្តិចបន្តួចព្រមជាមួយកាដូលួងចិត្តបន្តិចទៅ នឹងកាន់តែផ្តល់ភាពសំខាន់ដល់គេកាន់តែខ្លាំងឡើង។

អានន្ទ សម្រេចចិត្តបែរមុខទៅរកហាងលក់ផ្កាវិញ...

* * *

ម៉ោង [11:57] នាទី

ផ្កាកែវបែកញើសជោកថ្ងាស ហើយខ្វល់ខ្វាយចិត្តយ៉ាងខ្លាំង រហូតគូទលែងជាប់កៅអី។

ពេលនេះនំចំណី ដែលធ្វើសម្រាប់ទទួល ក៏រៀបចំពេញប្រៀបអស់ដែរ នៅសល់តែពេល អានន្ទលេចមុខមកប៉ុណ្ណោះ។

«អូនកែវ!» សំឡេងកាចដែលលាន់ឮពីក្រោយខ្នង ធ្វើឲ្យអ្នកស្ដាប់ភ្ញាក់ព្រើត។ មើលតាមកាយវិការខុសប្រក្រតីរបស់នាង បានបញ្ជាក់យ៉ាងច្បាស់នៅក្នុងខ្សែភ្នែករបស់ មុទិតា រួចទៅហើយ។

អាណាព្យាបាលក្រមុំដើរចេញពីក្នុងផ្ទះដោយទឹកមុខក្រញូវដូចកំពុងខឹង។

«អូនកែវ មិនមែនឲ្យបងធ្វើនំចំណីទាំងអស់នេះ សម្រាប់ញ៉ាំខ្លួនឯងទេមែនទេ? អូនកែវ លួចណាត់នរណាឲ្យមកជួបនៅផ្ទះមែនទេ?»

«បងតា... គឺ...» ក្មេងស្រីភ័យប្រកែកមិនចេញ។

«ប្រាប់ហើយតើ ថាកុំទៅទាក់ទងនឹងនរណាទៀត! ការដែលសម្រេចចិត្តឲ្យគេមកផ្ទះ ព្រោះ «កើតរោគ» បែបនោះ ឡើងមកទៀតហើយ មែនទេ? ហេតុអ្វីក៏ អូនកែវ ចូលចិត្តធ្វើបាបផ្លូវចិត្តខ្លួនឯងបែបនេះ?»

«ប...បងតា...»

* * *

ផ្ទះនៅក្នុងសង្កាត់នេះ ភាគច្រើនសុទ្ធតែធំស្កឹមស្កៃ ដូចវាំងស្ដេចនៅក្នុងកុនទូរទស្សន៍។ បើតាមការប៉ាន់ស្មានតម្លៃហើយ អានន្ទគិតថា មនុស្សដូចគេ មួយជាតិនេះពិតជាគ្មានសមត្ថភាពបានធ្វើជាម្ចាស់ភូមិគ្រឹះអស់ទាំងនេះទេ។

ខ្សែភ្នែកបញ្ឈប់ត្រង់បាច់ផ្កានៅក្នុងដៃ...

ការពិតក៏មិនប្រាកដដែរ... បន្ទាប់ពីថ្ងៃនេះ គេអាចនឹងមានសិទ្ធិ!

កំលោះដើរមើលផ្លាកលេខតាមផ្ទះនីមួយៗ... អឺមមម... ប្រហែលជាផ្ទះធំជាងគេនេះហើយ!

តើនឹងមានរឿងអីកើតឡើង... បើគេដើរទៅដល់មុខផ្ទះ ចំពេលដែលទ្រនិចនាឡិកាវែងនិងខ្លីត្រួតស៊ីគ្នាចំលេខ១២!!

* * *

សំឡេងគ្រាំងលាន់ឡើងស្ទើរកក្រើកដី ទាញខ្សែភ្នែក ផ្កាកែវ និង មុទិតា ឲ្យងាកមកមើលហេតុការណ៍នៅមាត់ទ្វាររបងផ្ទះ។ គិលានុបដ្ឋាយិកាក្រមុំបើកភ្នែកធំៗចំហមាត់កាំង តែមិនស្មើនឹង ផ្កាកែវ ដែលបេះដូងស្ទើរតែធ្លាយចេញពីទ្រូង។

រូបភាពនៅខាងមុខ... បុរសម្នាក់កំពុងតែលេចកប់បាត់ទៅក្នុងកង់រថយន្តម៉ាកទំនើបល្បីឈ្មោះមួយគ្រឿង ដែលមុជក្បាលចូលមកយ៉ាងលឿនស្លេវបុកពេញទំហឹង ទោះបីជាជាន់ហ្វ្រាំងក៏រថយន្តនៅតែអូសយកមនុស្សទៅរាប់សិបម៉ែត្រ... ហើយបន្សល់នូវសារជាតុរាវលាបពណ៌ក្រហមឆ្អិនឆ្អៅ ពេញថ្នល់បេតុង។

«បងអានន្ទ!!!»

* * *

ទោះបីជា មុទិតា ដាស់តឿន និង ហាមឃាត់យ៉ាងណា ក៏ ផ្កាកែវ នៅតែទទូចអង្វរហើយអង្វរទៀត ទាល់តែទីបំផុត បុគ្គលជាអាណាព្យាបាល ក៏យល់ព្រមនាំនាងទៅចូលរួមបុណ្យសពរបស់ អានន្ទ ។ ក្រោយពីអុជធូប និង ថ្វាយផ្កា នៅមុខមឈូសសាកសពរួចហើយ ផ្កាកែវ ក៏ព្រមហើបមាត់និយាយរឿងរ៉ាវទាំងអស់អំពីមិត្តភក្តិកំលោះ ដែលស្គាល់គ្នាតាមរយៈគេហទំព័រ Facebook ។

«ឲ្យ កែវ សុំទោសផងដែលមិនជឿសម្ដី បងតា តែ កែវ ឯកោខ្លាំងពេក កែវ ក៏ចង់មានមិត្តភក្តិដូចគេឯងដែរ...» កុមារីឈ្ងោកមុខចុះ «មិននឹកស្មានថា បងអានន្ទ... ហ៊ឹៗ... មិនគិតសោះថាគាត់...»

***មិននឹកស្មានសោះថា គេនឹងក្លាយជាស្រមោលមួយទៀតដែលអន្ទោលតាមរាងកាយរបស់នាង ... រាងកាយដែលមានតែភាពឯកោ ហើយភាពឯកោដែលតែងតែសម្លាប់មនុស្សគ្រប់គ្នា ដែលនាងស្គាល់...***

យូរប៉ុណ្ណា ដែលទ្រាំទុក្ខវេទនាក្នុងការឃើញរូបភាព និង ដឹងឮនូវសេចក្ដីស្លាប់ដែលកំពុងតែមកឆក់យកជីវិតរបស់មនុស្សនៅជុំវិញខ្លួន... អ្នកខ្លះនិយាយនៅក្នុងផ្លូវល្អថា វាជាសមត្ថភាពពិសេសមួយដែលអ្នកដទៃគ្មាន។ មុទិតា ប្រាប់ថា វាប្រៀបដូចជំងឺដ៏កាចសាហាវ ខណៈដែលប៉ាម៉ាក់ និង អ្នកផ្សេងទៀត ប្រាប់ថា វាជាបណ្ដាសាដែលសណ្ឋិតជាប់ខ្លួនមកជាមួយ «បិសាច»!

ប្រហែលជារឿងធម្មតា បើ ផ្កាកែវ ជាក្មេងស្រីដែលមានផ្លូវចិត្តរឹងមាំដូចមនុស្សទូទៅ តែសម្រាប់មនុស្សដែលមានបេះដូងទន់ខ្សោយដូចនាង... ការដឹងឮរឿងបែបនេះរាល់ថ្ងៃរាល់ពេល នឹងផ្ដល់ផលអាក្រក់ដល់ខ្លួនឯងមិនខាន។

មុទិតា ផ្ដល់យោបល់ឲ្យនាងនៅតែក្នុងផ្ទះ កាត់ផ្ដាច់ទំនាក់ទំនងនិងសម្ព័ន្ធភាពជាមួយអ្នកដទៃឲ្យនៅសល់តិចបំផុត ព្រោះបើហេតុការណ៍នេះកើតឡើងចំពោះមនុស្សដែលមិនសូវសំខាន់ចំពោះនាង ផលប៉ះពាល់ចំពោះផ្លូវចិត្តរបស់ ផ្កាកែវ ក៏មានតិចតួច។

ផ្កាកែវ នោះហើយដែលខុសខ្លួនឯង នាងនៅតែប្រឹងជម្នះដើម្បីចេញទៅជួបរឿង ដ៏សែនស្លុតរន្ធត់។

វាជាបាបកម្មពិតមែន... ជាបាបកម្មដែលនាងដឹង តែមិនអាចឈោងដៃទៅជួយជីវិតរបស់នរណាម្នាក់បានឡើយ។ ច្រើនដងហើយ ដែលនាងព្យាយាមសាកល្បង ប្រសិនបើដៃម្ខាងរបស់ខ្លួនមាន ឬអាចស៊ូឈ្នះនឹងកណ្ដាប់ដៃមច្ចុរាជ។ ផ្កាកែវ ទទួលអារម្មណ៍ថា ខ្លួនឯងនេះហើយជាអ្នកខុស គឺវាខុសនៅលើរូបនាង!!

«ផ្លូវដែលល្អ អូនកែវ ត្រូវធ្វើតាមអ្វីដែលបងប្រាប់ណ៎ា!» មុទិតា និយាយដោយសំឡេងម៉ឺងម៉ាត់ តែពោរពេញដោយក្ដីបារម្ភ «ពិភពរបស់អូនកែវ មានអ្វីៗគ្រប់បែបយ៉ាងទៅហើយ ដូច្នេះឈប់ទៅស្វែងរកអ្វីទៀត មកបន្ថែមភាពឈឺចុកចាប់ឲ្យខ្លួនឯងធ្វើអី!»

«តើ កែវ គួរធ្វើយ៉ាងម៉េចទៅ??» ពេលនឹកទៅដល់រូបភាពចុងក្រោយរបស់ អានន្ទ ក៏ធ្វើឲ្យនាងឈឺចុកចាប់ទៅដល់ជម្រៅបេះដូង។ តើកម្មពៀអ្វីហ្ន៎... ដែលធ្វើឲ្យនាងទៅជាបែបនេះ??

«ផ្ដាច់ការទាក់ទងជាមួយអ្នកដទៃនោះអី! ស្គាល់មនុស្សតិចប៉ុណ្ណា ការឈឺចាប់ក៏មានតិចប៉ុណ្ណោះ! ជាពិសេសមនុស្សដែល... អូនកែវឃើញ... ឈប់រវីរវល់ជាមួយគេ កុំព្យាយាមសាកល្បងរកវិធីជួយសង្គ្រោះ គ្មានប្រយោជន៍ទេ... ព្រោះកាន់តែធ្វើបែបនោះ អូនកែវ កាន់តែយកបេះដូងទៅពាក់ព័ន្ធជាមួយ!»

«អូនកែវ...» មុទិតា ទាញដៃក្មេងស្រីដែលនាងស្រលាញ់ដូចប្អូនបង្កើតឲ្យងាកមកសម្លឹងភ្នែក។ រំពេចនោះ អារម្មណ៍មួយស្រាប់តែទទួលដឹងថា ដៃទន់ៗនោះប្រែជាត្រជាក់ស្រេប ធ្វើឲ្យក្មេងស្រីបើកភ្នែកធំៗដោយក្ដីតក់ស្លុត។

«ជឿបងណា... ត្រូវចាប់ផ្ដើមធ្វើតាំងពីពេលនេះទៅ!» មុទិតា និយាយដោយសម្ដីលួងលោមសម្លឹងភ្នែកសើមជោកដោយទឹកភ្នែក ដែលកំពុងសម្លឹងមកវិញយ៉ាងសោកសៅ។

«ច... ចាប់ផ្ដើម... តាំងពីពេលនេះឬ?...»

«មែនហើយ...» មុទិតា អង្គុយចុះក្ដោបស្មាទាំងសងខាងរបស់ស្រីតូច។

«ចាប់ផ្ដើមតាំងពីពេលនេះ!!»

រំពេចនោះ មុទិតា ក៏ទទួលដឹងនូវភាពខុសប្រក្រតីមួយយ៉ាងចម្លែក។ រាងកាយរបស់ ផ្កាកែវ ប្រែជារឹងក្រញឹសជាលំដាប់ កែវភ្នែកសោកសៅញ័ររញ្ជួយ ហាក់ដូចជាចង់ប្រាប់អ្វីម្យ៉ាង ហើយបែរជាក្ដាប់មាត់ទប់វិញ។ ដៃរឹងតូចៗទាញដៃរបស់ មុទិតា ចេញ ហើយបោះជំហានថយក្រោយ ដោយទឹកភ្នែកដក់ពេញប្រទ្បង់ មុននឹងបែរខ្នងឈានជើងវែងៗដើរចេញទៅ ដោយមិននិយាយអ្វីមួយម៉ាត់។

តែត្រឹមប៉ុណ្ណោះក៏សមល្មម...

សមល្មមនឹងធ្វើឲ្យ មុទិតា បើកភ្នែកធំៗ

រឹងខ្លួនស្លុកហើយបះរោមច្រាងពេញរាងកាយ!!

**ចប់**